ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# សេចក្តីប្រកាសព័ត៌មាន

យោងតាមសេចក្តីជូនដំណឹង ស្តីពីការព្យាករណ៍អាកាសធាតុ របស់ក្រសួងធនធានទឹកនិងឧតុនិយម ផ្សាយនាថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២៣ បានឱ្យដឹងថា រដូវវស្សាឆ្នាំ២០២៣នេះ នឹងចូលមកដល់យឺតនៅសប្តាហ៍ទី២ នៃខែឧសភា ជាមួយនឹងបរិមាណទឹកភ្លៀងពីតិចទៅមធ្យម និងមានកួនរដូវប្រាំងដែលអាចកើតឡើង ហើយអូសបន្លាយចាប់ពីដើមខែកក្កដា រហូតដល់ដើមខែសីហា។ ស្ថានភាពបែបនេះអាចបង្កផលប៉ះពាល់ដល់ផលិតកម្មដំណាំកសិកម្ម។

ដើម្បីចូលរួមចំណែកក្នុងការត្រៀមបង្ការនិងឆ្លើយតប ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សូមជូនដំណឹងដល់ប្រជាកសិករ អាជ្ញាធរមូលដ្ឋាន និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាមអនុវិស័យដូចខាងក្រោម៖

**ក. អនុវិស័យកសិកម្ម៖**

- កសិករត្រូវត្រៀមបង្ការនិងឆ្លើយតប តាមរយៈការលើកទប់និងថែទាំភ្លឺស្រែឱ្យបានល្អ ដើម្បីរក្សាទឹកទុក ព្រមទាំងរៀបចំម៉ាស៊ីនបូមទឹកសម្រាប់បូមទឹកសង្គ្រោះនៅពេលចាំបាច់។
- សម្រាប់ការដាំដុះស្រូវដើមរដូវវស្សា (ប្រភេទពូជស្រូវស្រាល) កសិករមិនគួរប្រថុយប្រថានដាំដុះដោយពឹងលើប្រភពទឹកតិចតួចឡើយ ព្រោះអាចប្រឈមនឹងការខូចខាតដោយសាររាំងស្ងួត។ ដោយឡែក តំបន់ដែលមានប្រភពទឹកគ្រប់គ្រាន់ កសិករគួរប្រញាប់ប្រញាល់ដាំដុះនៅចុងខែមេសា ឬដើមខែឧសភានេះ ដើម្បីអាចប្រមូលផលស្រូវនៅចុងខែកក្កដា ឬខែសីហា។
- សម្រាប់តំបន់ដាំដុះស្រូវអាស្រ័យទឹកភ្លៀង កសិករគួររួតរះភ្ជួរដាស់ដី ដើម្បីត្រៀមដាំដុះក្នុងខែមិថុនា ឬខែកក្កដា ដោយប្រើប្រាស់ប្រភេទពូជស្រូវកណ្តាលប្រកាន់រដូវ ដូចជា៖ ពូជស្រូវផ្ការំដួល និងប្រភេទពូជស្រូវផ្សេងៗទៀត ដែលនឹងត្រូវប្រមូលផលក្នុងខែវិច្ឆិកា។
- កសិករដែលដាំដុះដំណាំបន្លែ គួរប្រើប្រាស់ប្រព័ន្ធស្រោចស្រពសន្សំសំចៃទឹក ប្រក់សំណាញ់ដើម្បីទប់កម្តៅ និងប្រើសារធាតុគម្របដីពីចំបើង ឬកាកសំណល់ដំណាំស្ងួត ឬគម្របប្លាស្ទិក ដើម្បីរក្សាសំណើមដីឱ្យបានយូរ។
- កសិករដែលស្ថិតនៅតំបន់ឆ្ងាយពីប្រភពទឹក ដូចជា ទន្លេ ស្ទឹង បឹង ឬអាងទឹក ត្រូវត្រៀមលក្ខណៈរក្សាទឹកទុកឱ្យបានច្រើននៅក្នុងត្រពាំង ឬអាងស្តុកទឹកនៅតាមគ្រួសារ ឬសហគមន៍ សម្រាប់ទុកស្រោចស្រពក្នុងពេលរាំងស្ងួត។
- មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានី-ខេត្ត និងអាជ្ញាធរមូលដ្ឋាន ត្រូវសហការជាមួយអង្គភាពជំនាញ ដើម្បីចុះត្រួតពិនិត្យប្រភពទឹក វាយតម្លៃផ្ទៃដីដាំដុះដែលអាចមានលទ្ធភាពស្រោចស្រព និងសម្របសម្រួលបែងចែកការប្រើប្រាស់ទឹក ព្រមទាំងការផ្តល់បច្ចេកទេសផលិតកម្មដំណាំតាមបែបទំនើបបន្សាំនឹងការប្រែប្រួលអាកាសធាតុ។

➢ ករណីមានចម្ងល់ឬបញ្ហាបន្ទាន់ណាមួយ សូមស្វែងរកអន្តរាគមន៍ពីមន្ត្រីនៃអគ្គនាយកដ្ឋានកសិកម្ម តាមរយៈ លោក ម៉ាក់ សឿន (០១២ ៨២៦ ៦១៧) និងលោក ស៊ន វិចិត្រ (០១២ ២៦៣ ៥៩២)។

**ខ. អនុវិស័យជលផល**

- ធាតុអាកាសនៅចន្លោះខែមេសាដល់ខែមិថុនាមានសភាពក្តៅខ្លាំង ជាហេតុធ្វើឱ្យទឹកក្នុងស្រះរាក់។ ត្រីក្នុងស្រះងាយងាប់ដោយសារពុលនិងខ្វះអុកស៊ីសែន ដែលទាមទារឱ្យមានការបញ្ចូលទឹកបន្ថែម ឬធ្វើទឹកក្នុងស្រះឱ្យមានចលនា ដើម្បីបង្កើនអុកស៊ីសែន។
- ត្រូវតាមដានកម្ពស់ទឹកនិងស្ថានភាពត្រីមេពូជនៅតាមកន្លែងអភិរក្សជលផល ព្រមទាំងត្រៀមប្រភពទឹក សម្រាប់បូមចូល ក្នុងករណីរីងរាក់ខ្លាំងឬមានត្រីពុលងាប់។

➢ ករណីមានបញ្ហាដូច្នេះកើតឡើង សូមស្វែងរកអន្តរាគមន៍ពីនាយខណ្ឌរដ្ឋបាលជលផល នៅតាមរាជធានី-ខេត្ត ឬទាក់ទងមករដ្ឋបាលជលផល តាមរយៈទូរសព្ទលេខ ០១២ ៨២៩ ៩៧១ ឬ ០១២ ៩០៨ ១២១។

**គ. អនុវិស័យសុខភាពសត្វ និងផលិតកម្មសត្វ**

- ភាពរាំងស្ងួតអាចបណ្តាលឲ្យសត្វខ្វះចំណីនិងទឹក ភាពធន់ទៅនឹងជំងឺថយចុះ។ ចំណែកការឆ្លងជំងឺមានហានិភ័យខ្ពស់ ជាពិសេសបក្សី ដូច្នេះសូមយកចិត្តទុកដាក់ថែទាំសត្វឲ្យបានល្អ ដោយផ្តល់ទីជម្រក ផ្តល់ទឹកនិងចំណី និងចាក់វ៉ាក់សាំងឱ្យបានគ្រប់គ្រាន់។

➢ ក្នុងករណីមានបញ្ហាអំពីការថែទាំសុខភាពសត្វនិងសង្ស័យមានជំងឺ សូមទាក់ទងទៅកាន់ភ្នាក់ងារផ្តល់សេវាបសុពេទ្យនៅជិតបំផុត ដូចជាភ្នាក់ងារសុខភាពសត្វភូមិ ពេទ្យសត្វស្រុក និងការិយាល័យផលិតកម្មនិងបសុព្យាបាលខេត្ត មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត ឬទាក់ទងមកកាន់លោក នូ វនិកា ប្រធាននាយកដ្ឋានសុខភាពសត្វ និងសុខភាពសាធារណៈបសុព្យាបាល (០១២ ៤៨៣ ៥៧៨) ឬ លោក សុខ ដារ៉ូ ប្រធានការិយាល័យអង្កេតតាមដាន និងប្រយុទ្ធប្រឆាំងជំងឺសត្វ (០១២ ៥៥៥ ៦៨៩)។

អាស្រ័យដូចបានជម្រាបជូនខាងលើ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សង្ឃឹមជឿជាក់ថា ប្រជាកសិករ អាជ្ញាធរមូលដ្ឋាន មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអ្នកពាក់ព័ន្ធផ្សេងៗនឹងត្រៀមបង្ការជាមុន និងឆ្លើយតប ព្រមទាំងចូលរួមសហការក្នុងការកាត់បន្ថយផលប៉ះពាល់លើផលិតកម្មដំណាំកសិកម្ម វារីវប្បកម្ម សុខភាពសត្វ និងផលិតកម្មសត្វ ដោយសារឥទ្ធិពលនៃអាកាសធាតុនេះ៕

ថ្ងៃពុធ ៧កើត ខែពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ, ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២៣